# ព្រះរាជក្រឹត្យ

នស/រកត/០៧១០/៥៩៥

## ស្តីពី

## របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ក្រឹត្យលេខ១០ ក្រ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ០៧/នស/ ៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅគ្រប់គ្រងរបបសន្តិសុខសង្គម សម្រាប់អតីតយុទ្ធជន ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងដូចតទៅ ៖

-អនុវត្តគោលនយោបាយជាតិ របស់រាជរដ្ឋាភិបាលចំពោះអតីតយុទ្ធជន

-បង្កើនប្រសិទ្ធភាពក្នុងការបើករបបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនឲ្យបានឆាប់រហ័ស និងមានតម្លាភាព

-ចូលរួមចំណែកក្នុងយុទ្ធសាស្ត្រជាតិ កំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ

-លើកកម្ពស់ជីវភាពខាងសម្ភារៈ ស្មារតីរបស់អតីតយុទ្ធជន និងបង្កើតសំណាញ់សុវត្ថិភាពសង្គម

-បង្កើតភាពជាដៃគូ ជាមួយបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោកលើវិស័យអតីតយុទ្ធជន ។

**មាត្រា៣.-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ ៖

-អតីតយុទ្ធជននៃកងយោធពលខេមរភូមិន្ទ

-អតីតយុទ្ធជននៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-អតីតយុទ្ធជននៃក្របខណ្ឌមន្ត្រីរាជការស៊ីវិល បុគ្គលិកជាប់កិច្ចសន្យា កងជីវពល កងសេនាជន និងប្រជាពលរដ្ឋដែលបានចូលរួមប្រយុទ្ធ ឬបម្រើការងារប្រយុទ្ធដើម្បីប្រទេសជាតិ

-គ្រួសារអតីតយុទ្ធជន។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL *

## ជំពូកទី២
## ស្ថាប័នអនុវត្ត

**មាត្រា៤.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំបង្កើតបេឡាជាតិអតីតយុទ្ធជន ដើម្បីធានាការបើករបបសន្តិសុខសង្គម ជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន ។

**មាត្រា៥.-**

ការគ្រប់គ្រង និងការផ្តល់របបសន្តិសុខសង្គម សម្រាប់អតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន ត្រូវស្ថិតនៅក្រោមបេឡាជាតិអតីតយុទ្ធជនសរសេរកាត់ថា **ប.ជ.អ.**។ **ប.ជ.អ.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលហើយដែលត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

## ជំពូកទី៣
## របបសន្តិសុខសង្គម

**មាត្រា៦.-**

អតីតយុទ្ធជន អាចទទួលរបបសន្តិសុខសង្គមលើតាវកាលិក ដូចខាងក្រោម ៖

-ការចូលនិវត្តន៍
-ការបាត់បង់សមត្ថភាពការងារ
-មាតុភាព
-អាពាហ៍ពិពាហ៍គ្រាដំបូង
-ពលី
-មរណៈ
-ពិការភាព
-ជំងឺ និង
-គ្រួសាររបស់ជនទាំងនេះ ។

ការបន្ថែមរបបតាវកាលិកនៃរបបសន្តិសុខសង្គម និងតាវកាលិកផ្សេងៗទៀត សម្រាប់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៧.-**

អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនត្រូវទទួលរបបសន្តិសុខសង្គមតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមានតាមរយៈ **ប.ជ.អ.** ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា៨.-**

**ប.ជ.អ.** មានប្រភពធនធានមកពី ៖

-ថវិកាជាតិ
-ភាគទានរបស់រាជរដ្ឋាភិបាល
-ភាគទានរបស់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន

-អំណោយសប្បុរសធម៌

-អំណោយពីដៃគូអភិវឌ្ឍ អង្គការជាតិ និងអង្គការអន្តរជាតិនានា

-ផលចំណេញពីការវិនិយោគ និងអាជីវកម្មស្របច្បាប់ និង

-ប្រភពផ្សេងៗទៀត ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា៩.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបន្តការគ្រប់គ្រង និងការផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន រហូតដល់ ប.ជ.អ. ដំណើរការ ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១១.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកត/០៧១០/៦០៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៥៤៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កក្កដា ឆ្នាំ២០១០

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊ុន ជិនគេន**

ប/ក

# វាក្យសព្ទសំខាន់ៗ

- របបសន្តិសុខសង្គម សំដៅដល់គោលនយោបាយជាតិ ដែលផ្តល់នូវតាវកាលិកផ្សេងៗដល់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនដើម្បីធានានូវសុខុមាលភាពសង្គម។
- តាវកាលិក សំដៅដល់ផលប្រយោជន៍ឬរបបកំណត់ដែលរដ្ឋផ្តល់ដល់អតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន។
- អតីតយុទ្ធជន សំដៅដល់អតីតយោធិន នគរបាលជាតិ មន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា កងសេនាជន កងជីវពល និងប្រជាពលរដ្ឋកម្ពុជា ដែលបានចូលរួមប្រយុទ្ធឬបម្រើការងារប្រយុទ្ធដើម្បីប្រទេសជាតិតាមការកំណត់ដោយច្បាប់។
- សោធននិវត្តិ សំដៅដល់ប្រាក់ប្រចាំខែដែលរដ្ឋផ្តល់ដល់អតីតយុទ្ធជនចូលនិវត្តន៍ដែលកំណត់ដោយច្បាប់។
- សោធនបាត់បង់សមត្ថភាពការងារ សំដៅដល់ប្រាក់ប្រចាំខែដែលរដ្ឋផ្តល់ដល់អតីតយុទ្ធជនដែលបាត់បង់សមត្ថភាពការងារដោយសារជំងឺរ៉ាំរ៉ៃ ចាស់ជរាគ្រោះថ្នាក់ផ្សេងៗ មិនគ្រប់លក្ខណៈជនពិការ។
- បេឡាជាតិអតីតយុទ្ធជន សំដៅដល់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលគ្រប់គ្រងនិងបើករបបសន្តិសុខសង្គមជូនអតីតយុទ្ធជន។
- ភាគទាន សំដៅដល់ប្រាក់ដែលត្រូវបង់ចូលបេឡាតាមការកំណត់។
- វិភាគទាន សំដៅដល់ការចូលរួមចំណែកជាថវិកា សេវា ឬសម្ភារៈផ្សេងៗ ដែលផ្តល់ដល់បេឡាដោយការស្ម័គ្រចិត្ត។
- សមាជិក* សំដៅដល់នីតិសមាជិកត្រូវនឹងពាក្យបារាំងថា Membre de Droit ដែលយើងនឹងប្រើនៅក្នុងអនុក្រឹត្យបែបនេះទៅអនាគត សម្រាប់ជំនួសពាក្យសមាជិកស្វ័យប្រវត្តិនៅក្នុងព្រះរាជក្រឹត្យនស/រកត/១២៩៧/៩១ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។